# បង្រៀនតាមរបៀបព្រះវិញ្ញាណ

*ដោយ ម៉ាថាយ អូ រីឆាតសុន*
*ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទូទៅនៃសាលាថ្ងៃអាទិត្យ*

ជាច្រើនឆ្នាំមុន ខ្ញុំបាននៅជាមួយនឹងដៃគូរបស់ខ្ញុំ នៅឯមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនា នៅពេលដែលខ្ញុំបានឮសម្លេងក្មេងម្នាក់ស្រែកថា « លោកយាយតើនោះគឺជាពួកអ្នកផ្សព្វផ្សាយសាសនាពិត មែនទេ ? » ខ្ញុំបានងាកទៅមើលក្មេងស្រីម្នាក់កំពុងតែកាន់ដៃជីតារបស់នាង ហើយចង្អុលមកខ្ញុំ និងដៃគូ ។ ខ្ញុំញញឹម ហើយលូកដៃទៅកាន់នាង ដោយមើលចំកែវភ្នែករបស់នាង ហើយនិយាយថា « ជំរាបសួរ ខ្ញុំឈ្មោះអែលឌើរ រីឆាតសុន  ហើយយើងគឺជាពួកអ្នកផ្សព្វផ្សាយសាសនា ពិតប្រាកដ » ។ ពេលគាត់ក្រឡេកមកមើលខ្ញុំ គាត់មានក្តីរំភើបថា គាត់បានចូលរួមនឹងពួកអ្នកផ្សាយសាសនាពិតមែន ។ ខ្ញុំបានដើរចេញពីបទពិសោធន៍នោះដោយមានការតាំងចិត្តសារជាថ្មីម្តងទៀត ។ ខ្ញុំចង់ធ្វើជាប្រភេទអ្នកផ្សព្វផ្សាយសាសនាដែលព្រះអង្គសង្គ្រោះ ក្រុមគ្រួសារខ្ញុំ និងក្មេងស្រីតូចម្នាក់នេះរំពឹងចង់ឲ្យខ្ញុំធ្វើ ។ នៅពីរឆ្នាំបន្ទាប់នោះ ខ្ញុំខិតខំធ្វើការដើម្បីឲ្យក្លាយជាអ្នកផ្សព្វផ្សាយសាសនាបែបនោះ ធ្វើបែបនោះ ហើយជាពិសេស ត្រូវបង្រៀនឲ្យដូចជាអ្នកផ្សព្វផ្សាយសាសនាពិតប្រាកដ ។

នៅពេលត្រឡប់មកផ្ទះវិញ វាកាន់តែបង្ហាញយ៉ាងច្បាស់ថា ទោះបីជាខ្ញុំបានចាកចេញពីបេកកម្មក្តី ក៏បេសកកម្មរបស់ខ្ញុំមិនបានឃ្លាតឆ្ងាយពីខ្ញុំឡើយ ។ ការពិត ទោះបីជាបន្ទាប់ពីប៉ុន្មានឆ្នាំនេះ ខ្ញុំនៅតែគិតថា បេសក-កម្មរយៈពេលពីរឆ្នាំរបស់ខ្ញុំគឺជារយៈពីរឆ្នាំដែលប្រសើរបំផុត សម្រាប់ ជីវិតរបស់ខ្ញុំ ។ មេរៀនដែលពុំបានរំពឹងទុកមួយចេញពីបេសកកម្មរបស់ខ្ញុំ គឺសម្លេងរបស់ក្មេងស្រីរូបនោះ ។ រហូតមកដល់ឥឡូវនេះ ខ្ញុំនៅតែឮសម្លេងនោះនៅក្នុងគំនិតថា « លោកយាយ តើនោះជាអ្នកកាន់បព្វជិតភាព ពិតប្រាកដ មែនទេ ? » « លោកយាយ តើនោះគឺជាស្វាមី ពិតប្រាកដ មែនទេ ឬជាឪពុកពិតប្រាកដមែនទេ ? » ឬ « លោកយាយ តើនោះគឺជាសមាជិកពិតប្រាកដ នៃសាសនាចក្រមែនទេ ? »

ខ្ញុំបានរៀនគន្លឹះនៃការប្រែក្លាយជាមនុស្ស ពិតប្រាកដ នៅរាល់ទិដ្ឋភាពនៃជីវិតរបស់យើង គឺជាសមត្ថភាពដើម្បីបង្រៀន តាមរបៀបមួយពុំដាក់កំហិតចំពោះការរៀនសូត្រ ។ អ្នកឃើញទេថា ជីវិតពិតប្រាកដ តម្រូវឲ្យមាន ការរៀនសូត្រពិតប្រាកដដែរ ដែលផ្អែកទៅលើការបង្រៀនពិតប្រាកដ ។ ទំនួលខុសត្រូវដើម្បីបង្រៀនដោយមានប្រសិទ្ធភាពគឺពុំមានដែនកំណត់ឡើយ ចំពោះអ្នកទាំងឡាយណាដែលមានមុខងារជាក់លាក់ ដូចជាគ្រូបង្រៀន ។[1] ជាការពិតណាស់ រាល់សមាជិកគ្រួសារគ្រប់រូប អ្នកដឹកនាំសាសនាចក្រ ( រួមទាំងយុវវ័យ និងកុមារ ) មានទំនួលខុសត្រូវដើម្បីបង្រៀន ។

ទោះបីជាយើងទាំងអស់គ្នាគឺជាគ្រូបង្រៀន ក៏យើងត្រូវតែដឹងយ៉ាងច្បាស់ថា គឺព្រះវិញ្ញាណបរិសុទ្ធជាអ្នកដែលជាគ្រូបង្រៀន ពិត ហើយជាសាក្សីនៃសេចក្តីពិតទាំងអស់ ។ អស់អ្នកទាំងឡាយណាដែលពុំយល់ច្បាស់ពីកិច្ចការនេះ ឬថែមទាំងគ្រប់គ្រងលើព្រះវិញ្ញាណបរិសុទ្ធ ហើយធ្វើអ្វីៗដោយខ្លួនឯងដោយអញ្ជើញព្រះវិញ្ញាណមកគង់នៅជាមួយពួកគេដោយការគួរសម ប៉ុន្តែគ្រាន់តែជាការជួយប៉ុណ្ណោះ ឬជឿថាពួកគេកំពុងតែបង្វែរការបង្រៀនរបស់ពួកគេទៅឲ្យព្រះវិញ្ញាណ ដែលជាការពិតគឺពួកគេគ្រាន់តែ « ធ្វើឲ្យបានរួចពីដៃប៉ុណ្ណោះ» ។ ឪពុកម្តាយ ពួកអ្នកដឹកនាំ និងគ្រូបង្រៀនទាំងអស់មានទំនួលខុសត្រូវដើម្បីបង្រៀន « បង្រៀនដោយព្រះវិញ្ញាណ » ។[2]

ពួកគេមិនគួរបង្រៀន ពីមុននិងក្រោយព្រះវិញ្ញាណឡើយ ប៉ុន្តែ « បង្រៀនដោយព្រះវិញ្ញាណ » ដើម្បីឲ្យព្រះវិញ្ញាណបង្រៀនការពិតដោយឥតឈប់ឈរ ។

មរ៉ូណៃ ជួយយើងយល់ពីរបៀបដែលយើងអាច « បង្រៀនដោយព្រះវិញ្ញាណ » ដោយពុំបាច់ផ្លាស់ប្តូរ  ធ្វើឲ្យខ្សោយ ឬបណ្តេញព្រះវិញ្ញាណបរិសុទ្ធធ្វើជា គ្រូបង្រៀន នោះទេ ។ មរ៉ូណៃ និយាយថា ពួកបរិសុទ្ធទទួលបទពិសោធន៍របស់ពួកគេ « តាមរបៀបនៃកិច្ចការនៃព្រះវិញ្ញាណ » ។ ការណ៍នេះតម្រូវឲ្យមានលើសពីការគ្រាន់តែមានព្រះវិញ្ញាណគង់នឹងយើង ។ ដើម្បីធ្វើឲ្យខ្លួនយើង « តាមរបៀប » នៃព្រះវិញ្ញាណបរិសុទ្ធមានន័យថា យើងប្រហែលជាត្រូវផ្លាស់ប្តូរវិធីនៃការបង្រៀនរបស់យើងដើម្បីធ្វើតាមគំរូដែលព្រះវិញ្ញាណបរិសុទ្ធបង្រៀន ។ នៅពេលដែលយើងសម្រួបរបៀបរបស់យើងតាមរបៀបរបស់ព្រះវិញ្ញាណបរិសុទ្ធអាចបង្រៀន និងថ្លែងទីបន្ទាល់ដោយឥតរុញរា ។ ការកែតម្រង់ដ៏មានសារៈសំខាន់នេះអាចត្រូវបានបង្ហាញដោយឧទាហរណ៍ខាងក្រោម ។

ជាច្រើនឆ្នាំកន្លងទៅហើយ កូនៗរបស់ខ្ញុំ ហើយខ្ញុំឡើងទៅកំពូលភ្នំខាងត្បូង ដែលមានកំពស់ 10,358 ហ្វីត ( 3,157 ម. ) នៅក្រុងអ័រេហ្គិន ។ បន្ទាប់ពីឡើងបានពីរបីម៉ោងយើងបានជួបនឹងជម្រាលមុំ 45 ដឺក្រេ មកពីកំទេចថ្មតូចៗកឡើងដោយបន្ទុះភ្នំភ្លើង ។  ដោយឃើញកំពូលភ្នំស្ថិតនៅក្នុងចក្ខុពេលយើងបន្តទៅមុខគឺគ្រាន់តែបានឃើញជំហានរបស់យើងលិចចុះចូលក្នុងកំទេចគ្រួស ធ្វើឲ្យយើងរអិលក្រោយអស់ពីរបីសង់ទី-ម៉ែត្រ ។ កូនប្រុសរបស់ខ្ញុំ

ដែលមានអាយុ 12 ឆ្នាំ ឡើងទៅដល់កំពូលភ្នំ ខណៈដែលខ្ញុំកំពុងនៅជាមួយកូនស្រីអាយុប្រាំបីឆ្នាំខ្ញុំ ។ មិនយូរប៉ុន្មាន ការអស់កម្លាំង និងបាក់ទឹកចិត្តក៏បានកើតឡើង ហើយនាងបានខូចចិត្ត ដោយគិតថានាងមិនអាចទៅលេងជាមួយនឹងបងប្រុសនាងនៅឯកំពូលភ្នំនោះទេ ។ បំណងប្រាថ្នាដំបូងរបស់ខ្ញុំគឺបីនាងទៅ ។

ស្មារតីរបស់ខ្ញុំចង់ធ្វើដូច្នោះ ប៉ុន្តែរូបកាយរបស់ខ្ញុំទន់ខ្សោយណាស់ ។ យើងបានអង្គុយចុះនៅលើថ្ម គិតអំពីស្ថានភាពរបស់យើង យើងគិតរៀបគម្រោងថ្មីទៀត ។ ខ្ញុំបានប្រាប់កូនឲ្យតោងកំបៅខោខាងក្រោយខ្ញុំឲ្យជាប់ ហើយ — អ្វីដែលសំខាន់បំផុត — ពេលដែលខ្ញុំលើកជើងបោះជំហានភ្លាម នោះនាងគួរតែបោះជំហានចូលស្នាមជើងចាស់របស់ខ្ញុំឲ្យរហ័ស ។ នាងបោះជំហានតាមរាល់ជំហានរបស់ខ្ញុំ ហើយពឹងទៅលើជំហានដែលបានមកពីការតោងកំបៅខោរបស់ខ្ញុំ ។ បន្ទាប់ពីធ្វើអ្វីដែលមើលទៅហាក់ដូចជាយូរអង្វែង នោះយើងក៏បានទៅដល់កំពូលភ្នំ ។ អារម្មណ៍របស់នាងពីជោគជ័យ និងការពេញចិត្តគឺមានតម្លៃដែលមិនអាចកាត់ថ្លៃបានឡើយ ។ ហើយជាការពិតណាស់ ក្នុងទស្សនរបស់ខ្ញុំ នាង និងបងប្រុសរបស់នាងគឺជាអ្នកឡើងភ្នំពិតប្រាកដ ។

ជោគជ័យរបស់កូនស្រីខ្ញុំគឺជាលទ្ធផលនៃការខិតខំព្យាយាមរបស់នាង ហើយថាតើនាងឡើងភ្នំបានល្អ តាមរបៀប ដែលខ្ញុំឡើងភ្នំបានយ៉ាងណា ។ នៅពេលដែលនាងបោះជំហានរបស់នាងស្មើរនឹងខ្ញុំ យើងសម្រេចបានជោគជ័យទាំងអស់គ្នា ដែលធ្វើឲ្យខ្ញុំប្រើ ប្រាស់កម្លាំងខ្ញុំទាំងមូល ។ ករណីនោះក៏ដូចជានៅពេលយើងបង្រៀន « តាមរបៀបកិច្ចការនៃព្រះវិញ្ញាណ » ។ នៅពេលដែលយើងសម្របការបង្រៀនរបស់យើងត្រូវនឹងព្រះវិញ្ញាណបរិសុទ្ធ នោះព្រះវិញ្ញាណពង្រឹងយើង ហើយក្នុងពេលដូចគ្នានោះគឺមិនបង្គាប់ឡើយ ។ ដោយមានទស្សននេះនៅក្នុងគំនិត សូមធ្វើការពិចារណាពីមូលដ្ឋានពីរ « ធ្វើការដោយព្រះវិញ្ញាណ » ដែលល្អគ្រប់គ្រាន់សម្រាប់យើងធ្វើតាម ។

ទីមួយ ព្រះវិញ្ញាណបង្រៀនបុគ្គលម្នាក់ៗតាមលក្ខណៈផ្ទាល់ខ្លួន ។ ការណ៍នេះធ្វើឲ្យយើងអាចដឹងពីសេចក្ដីពិតសម្រាប់ខ្លួនយើងបានដោយស្និទ្ធស្នាល ។ ដោយសារតែសេចក្តីត្រូវការ កាលៈ ទេសៈ និងការរីកចម្រើនរបស់យើងខុសៗគ្នា នោះព្រះវិញ្ញាណបរិសុទ្ធបង្រៀនអ្វីដែលយើងត្រូវដឹង និងធ្វើ ដើម្បីយើងអាចមានលទ្ធិភាពដ៏ពេញសក្តានុពលរបស់យើង។ សូមកត់សំគាល់ថា ខណៈដែលព្រះវិញ្ញាណកំពុងបង្រៀន « សេចក្តីពិតនៃគ្រប់ការណ៍ទាំងអស់ » [4] វាពុំមានន័យថាព្រះវិញ្ញាណបង្រៀនសេចក្តីពិតទាំងអស់ក្នុងពេលតែមួយនោះទេ ។ ព្រះវិញ្ញាណបង្រៀនសេចក្តីពិត « មួយបន្ទាត់ម្តងៗ មួយសិក្ខាបទម្តងៗ ឯណេះបន្តិច ឯណោះបន្តិច » ។[5]

អស់អ្នកទាំងឡាយណាដែលបង្រៀនតាមរបៀបរបស់ព្រះវិញ្ញាណដឹងថា ខ្លួនបង្រៀនដល់មនុស្ស ពុំមែនគ្រាន់តែបង្រៀនមេរៀននោះទេ ។ ដូច្នោះហើយ ពួកគេយកឈ្នះលើការជំរុញឲ្យបង្រៀនអ្វីៗក្នុងសៀវភៅ ឬបង្រៀនអ្វីទាំងអស់ដែលពួកគេបានរៀនពីប្រធានបទនោះ ហើយផ្តោតយកចិត្តទុកដាក់ទៅលើអ្វីៗដែលក្រុមគ្រួសារ ឬសមាជិកថ្នាក់ខ្លួនត្រូវដឹង និងធ្វើទៅវិញ ។ ឪពុកម្តាយ ពួកអ្នកដឹកនាំ និងគ្រូបង្រៀនទាំងឡាយដែលធ្វើតាមរបៀបបង្រៀនរបស់ព្រះវិញ្ញាណ នឹងរៀនយ៉ាងឆាប់ថា ការបង្រៀនពិតប្រាកដ គឺមានលើសពីការគ្រាន់តែនិយាយ ឬប្រាប់ ។ ជាលទ្ធផល ពួកគេមានចិត្តស្តាប់សង្កេតដោយយកចិត្តទុកដាក់ ហើយបន្ទាប់មកពិចារណាពីអ្វីដែលត្រូវធ្វើបន្ទាប់ ។[6] នៅពេលដែលពួកគេធ្វើបែបនេះ ព្រះវិញ្ញាណបរិសុទ្ធគឺក្នុងតួនាទីបង្រៀនដល់ទាំងអ្នកស្តាប់ និងគ្រូបង្រៀន នូវអ្វីដែលពួកគេគួរធ្វើ និងនិយាយ ។[7]

ទីពីរ ព្រះវិញ្ញាណបរិសុទ្ធបង្រៀនដោយការអញ្ជើញ ការបំផុសគំនិត ការលើកទឹកចិត្ត និងការបំផុសគំនិតយើងឲ្យធ្វើ ។ ព្រះគ្រីស្ទបានបញ្ជាក់ដល់យើងថា យើងនឹងដឹងការពិតទាំងស្រុងនៃគោលលទ្ធិទាំងឡាយពេល យើងធ្វើតាម ។ [8] ព្រះវិញ្ញាណដឹកនាំ ណែនាំ ហើយបង្ហាញយើងពីអ្វីដែលត្រូវធ្វើ ។ [9] ទោះជាយ៉ាងណាក្តី ការណ៍ទាំងនេះមិនអាចធ្វើជំនួសយើងនូវអ្វីដែលយើងអាចធ្វើឡើយ ។ អ្នកដឹងថា ព្រះវិញ្ញាណបរិសុទ្ធមិនអាចរៀនជំនួស យើង ទទួលអារម្មណ៍ជំនួស យើង ឬធ្វើជំនួស យើងឡើយ ពីព្រោះបើធ្វើបែបនេះនឹងខុសពីគោលលទ្ធិនៃសេរីភាព ។ ការណ៍ទាំងនេះ ធ្វើឲ្យមានឱកាស ហើយអញ្ជើញយើងឲ្យរៀន ទទួលអារម្មណ៍ និងធ្វើតាម ។

អស់អ្នកទាំងឡាយណាដែលធ្វើតាមរបៀបនៃព្រះវិញ្ញាណនេះ ជួយដល់អ្នកដទៃតាមរយៈ ការអញ្ជើញ ការលើកទឹកចិត្ត និងការផ្តល់ឱកាសឲ្យពួកគេប្រើប្រាស់សេរីភាពរបស់ខ្លួន ។ ឪពុកម្តាយ ពួកអ្នកដឹកនាំ និងគ្រូបង្រៀនទាំងឡាយដឹងថាពួកគេមិនអាចទទួលអារម្មណ៍ ជំនួស រៀន ជំនួស ឬក៏ប្រែចិត្ត ជំនួស គ្រួសារ អង្គប្រជុំ ឬសមាជិកថ្នាក់របស់ពួកគេឡើយ ។ ជាជាងការសួរថា « តើខ្ញុំអាចធ្វើអ្វីសម្រាប់កូនៗ សមាជិកថ្នាក់របស់ខ្ញុំ និងអ្នកដទៃ ? » ពួកគេសួរថា « តើខ្ញុំអាចអញ្ជើញ និងជួយមនុស្សដែលនៅជុំវិញខ្លួនខ្ញុំឲ្យរៀនសម្រាប់ខ្លួនរបស់ពួកគេយ៉ាងដូម្តេច ? » ឪពុកម្តាយទាំងឡាយដែលធ្វើតាមកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ ធ្វើឲ្យគេហដ្ឋានជាគ្រួសាររៀនឲ្យតម្លៃ ជំនួសឲ្យការគ្រាន់តែរៀនពីតម្លៃ ។ តាមរបៀបដូចគ្នានេះ ជាជាងការគ្រាន់តែនិយាយអំពីគោលលទ្ធិ គ្រូបង្រៀនទាំងឡាយជួយអ្នកឲ្យយល់ ហើយរស់នៅតាមគោលលទ្ធិនៃដំណឹងល្អ ។ ព្រះវិញ្ញាណបរិសុទ្ធគឺមិនដកថយឡើយ ប្រសិនបើបុគ្គលទាំងឡាយអនុវត្តសេរីភាពរបស់ពួកគេ ដោយត្រឹមត្រូវ ។

ស្ថានភាពបច្ចុប្បន្នរបស់ពិភពលោក យើងពិតជាត្រូវការការរៀន និងបង្រៀនពិតប្រាកដ នៅក្នុងគេហដ្ឋាន ការប្រជុំ និងថ្នាក់ដំណឹងល្អរបស់យើង ។ ខ្ញុំដឹងថាការព្យាយាមដើម្បីអភិវឌ្ឍខ្លួន ពេលខ្លះ អាចមើលទៅគួរថប់បារម្ភ ។ សូមកុំបាក់ទឹកចិត្តនឹងការរីកចម្រើនរបស់អ្នកឡើយ ។ ខ្ញុំគិតពីបទពិសោធន៍នៃការឡើងភ្នំរបស់ខ្ញុំជាមួយកូន ។ យើងបានព្រមព្រៀងគ្នាថា រាល់ពេលដែលយើងឈប់សម្រាក ជំនួសឲ្យការគិតថា យើងត្រូវទៅចម្ងាយណាទៀត យើងមើលទៅក្រោយ ហើយពីលើភ្នំចុះក្រោមវិញ ។ យើងមើលទៅទេសភាព ហើយនិយាយទៅគ្នាថា « យើងមកបានឆ្ងាយហើយ » ។ ហើយបន្ទាប់មកយើងដកដង្ហើមខ្លាំង រួចត្រឡប់ក្រោយភ្លាម ហើយមើលទៅលើ រួចចាប់ផ្ដើមឡើងបន្តទៅទៀត មួយជំហានម្ដងៗ ។ បងប្អូនប្រុសស្រីទាំងឡាយ អ្នកអាច ឪពុកម្ដាយ និងជាគ្រូបង្រៀនដ៏សកម្ម តាមរបៀបនៃការងាររបស់ព្រះវិញ្ញាណ។ ខ្ញុំដឹងថាអ្នកអាចធ្វើការនេះបាន ហើយជីវិតរស់នៅនឹងផ្លាស់ប្ដូរ។

ជីវិតរបស់ខ្ញុំបានត្រូវប្រសិទ្ធពរដោយ គ្រូបង្រៀនពិតប្រាកដ ដែលបានបង្រៀនជាមួយព្រះវិញ្ញាណ ជាពិសេស ដោយព្រះវិញ្ញាណ ។ ខ្ញុំសូមអញ្ជើញអ្នកឲ្យសម្របការបង្រៀនរបស់អ្នកតាមរបៀបនៃការបង្រៀនរបស់ព្រះវិញ្ញាណបរិសុទ្ធនៅគ្រប់អ្វីៗដែលអ្នកធ្វើ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គសង្គ្រោះរបស់យើង ហើយថាដំណឹងល្អរបស់ទ្រង់គឺត្រូវបានស្ដារឡើងវិញ ។ ពីព្រោះតែការណ៍នេះយើងត្រូវតែធ្វើជាឪពុកម្ដាយពិតប្រាកដ អ្នកដឹកនាំពិតប្រាកដ  គ្រូបង្រៀនពិតប្រាកដ និងជាអ្នករៀនពិតប្រាកដ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថាព្រះនឹងជួយអ្នកនៅក្នុងកិច្ចខិតខំអ្នក ក្នុងព្រះនាមដ៏ពិសិដ្ឋនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. សូមមើល *Teaching, No Greater Call* ( ឆ្នាំ 1999 ) ទំព័រ 3 ។

2. គោលលទ្ធិ និងសេចក្ដីសញ្ញា 50:14 ។

3. មរ៉ូណៃ 6:9 ។

4. មរ៉ូណៃ 10:5; សូមមើលផងដែរ គោលលទ្ធិ និងសេចក្ដីសញ្ញា 50:14; ពិតចំពោះសេចក្ដីជំនឿ ៖ សេចក្ដីយោងបទគម្ពីរ ( ឆ្នាំ 2004 ) ទំព័រ 82 ។

5. នីហ្វៃទី2 28:30 ។

6. សូមមើល ដេវីឌ អេ បែដណា Seminary and Institute Broadcast, Aug. 11, 2011; សូមមើលផងដែរ « Seek Learning by Faith » ការចាក់ផ្សាយពីប្រព័ន្ធអប់រំនៃសាសនាចក្រ ថ្ងៃទី 3 ខែ កុម្ភៈ ឆ្នាំ 2006 ។

7. សូមមើល លូកា 12:12

8. សូមមើល យ៉ូហាន 7:17 ។

9. សូមមើល នីហ្វៃទី2 32:1–5 ។